ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាស្ថានគរុកោសល្យ

ការគោរព ភាពស្មោះត្រង់ ការប្ដេជ្ញាចិត្ត នវានុវត្តន៍ និងប្រសិទ្ធផល

# ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស

ឆ្នាំ២០២២

# មុខកថា

ការអប់រំត្រូវបានចាត់ទុកជាកត្តាសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដែលរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងសង្គមពុទ្ធិ និងបរិបទសកលភាវូបនីយកម្ម។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពលើវិស័យអប់រំ ដើម្បីធានាថាកុមារកម្ពុជាគ្រប់រូបអាចទទួលបានការអប់រំមូលដ្ឋានប្រកបដោយគុណភាព សមភាព និងឥតគិតថ្លៃ ដូចមានចែងក្នុងច្បាប់ស្តីពីការអប់រំ និងស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំឆ្នាំ២០៣០ "ធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។

ក្រសួងអប់រំ យុវជន និងកីឡាបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់គុណភាពអប់រំ តាមរយៈការធ្វើកំណែទម្រង់ ដោយកំណត់យកគុណភាពគ្រូបង្រៀនជាអាទិភាព ឆ្ពោះទៅសម្រេចបានលទ្ធផលសិក្សារបស់សិស្សល្អប្រសើរ។ ក្នុងន័យនេះ គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតឱ្យក្លាយជាគ្រូបង្រៀនប្រកបដោយគុណសម្បទាវិជ្ជាជីវៈពេញលេញ។ ដូច្នេះ គ្រូឧទ្ទេសត្រូវមានលក្ខណៈសម្បត្តិខ្ពស់ ស្របតាមស្តង់ដាវិជ្ជាជីវៈមួយ។ ក្រសួងបានរៀបចំស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស នេះឡើង ក្នុងគោលបំណងធានាបាននូវគុណសម្បទាគ្រប់គ្រាន់សម្រាប់គ្រូឧទ្ទេស ដែលបម្រើការនៅវិទ្យាស្ថានគរុកោសល្យ និងជាត្រីវិស័យដល់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេសផងដែរ ដើម្បីឈានទៅការផ្តល់កម្មវិធីអប់រំគ្រូបង្រៀននៅតាមវិទ្យាស្ថានគរុកោសល្យ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡាជឿជាក់ថា **ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស** របស់វិទ្យាស្ថានគរុកោសល្យនេះ គឺជាឯកសារដ៏មានសារៈសំខាន់ ក្នុងការជួយជំរុញ និងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់គ្រូឧទ្ទេសឱ្យមានចំណេះដឹង ជំនាញវិជ្ជាជីវៈ គុណធម៌ សីលធម៌ និងស្មារតីទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីអប់រំគ្រូបង្រៀនរបស់វិទ្យាស្ថានគរុកោសល្យ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡា សូមកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមគាំទ្រ និងរួមចំណែកដល់ការរៀបចំឯកសារ ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសឱ្យសម្រេចបានជោគជ័យ។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


បុព្វកថា ..... i

១. សាវតារ ..... 1

២. គោលបំណង ..... 1

៣. គុណាសម្បទាគ្រូឧទ្ទេស របស់វិទ្យាស្ថានគរុកោសល្យ ..... 1

៤. មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូឧទ្ទេស ..... 2

៥. ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ..... 3

ស្តង់ដាទី១៖ ចំណេះដឹងវិជ្ជាជីវៈ ..... 4

ស្តង់ដាទី២៖ ការប្រតិបត្តិវិជ្ជាជីវៈ ..... 4

ស្តង់ដាទី៣៖ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ..... 4

ស្តង់ដាទី៤៖ សីលធម៌វិជ្ជាជីវៈ ..... 5

ស្តង់ដាទី៥៖ ការស្រាវជ្រាវអប់រំ ..... 6

ស្តង់ដាទី៦៖ ការអភិវឌ្ឍកម្មវិធីអប់រំ ..... 6

៦. យន្តការនៃការវាយតម្លៃលទ្ធផលអនុវត្តស្តង់ដា ..... 7

៦.១. ការវាយតម្លៃការងារផ្តោតលើលទ្ធផល ..... 7

៦.១.១. គោលដៅនៃការវាយតម្លៃការងារផ្តោតលើលទ្ធផល ..... 7

៦.២.១. ការពិនិត្យសំណុំឯកសារគ្រូឧទ្ទេស ..... 9

៦.២.២. របាយការណ៍ស្វ័យឆ្លុះបញ្ចាំង (ស្វ័យវាយតម្លៃ) ..... 9

៦.២.៣. ការវាយតម្លៃដោយគរុនិស្សិត ..... 9

៦.៣. សូចនាករ និងភស្តុតាង ..... 10

៦.៤. កម្រិតនៃការវាយតម្លៃ ..... 10

ឯកសារយោង ..... 11

ឧបសម្ពន្ធ១៖ សមាសភាពស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស វិទ្យាស្ថានគរុកោសល្យ ..... 12

ឧបសម្ពន្ធ២៖ សូចនាករ និងភស្តុតាង តាមស្តង់ដានីមួយៗ ..... 13




Khmer Law Association, www.khmerlaw.org

## ១. សាវតារ

គ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យនឹងក្លាយជាគ្រូឧទ្ទេសប្រកបដោយគុណសម្បទាពេញលេញ ដែលមានចំណេះដឹង និងស្តង់ដាវិជ្ជាជីវៈខ្ពស់ ឆ្លើយតបបំណិនសតវត្សទី២១។ ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសត្រូវបានអភិវឌ្ឍឡើងក្នុងគោលបំណងជួយគាំទ្រ និងវាយតម្លៃលទ្ធផលនៃការខំប្រឹងប្រែងរបស់គ្រូឧទ្ទេសក្នុងការអនុវត្តស្តង់ដានានា ដោយបន្សីគ្នាទៅនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ក្របខណ្ឌគុណវុឌ្ឍិសម្រាប់គ្រូឧទ្ទេស លក្ខណៈវិនិច្ឆ័យរបស់គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(ACC) ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន(TEPS) និងស្តង់ដាធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថានគរុកោសល្យ។ ស្តង់ដានេះក៏មានគោលបំណងផងដែរ ក្នុងការម្រេចស្តង់ដាកម្រិតខ្ពស់របស់គ្រូឧទ្ទេសលើការបង្រៀននិងរៀន និងការស្រាវជ្រាវប្រតិបត្តិ ដើម្បីពង្រឹងគុណភាពផ្ទៃក្នុងជាលក្ខណៈប្រព័ន្ធឱ្យមានភាពប្រសើរឡើង ប្រកបដោយចីរភាព។

## ២. គោលបំណង

ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសមានគោលបំណង៖

- លើកកម្ពស់ដំណើរការបង្រៀន និងរៀនរបស់គ្រូឧទ្ទេស ដើម្បីជួយឱ្យការសិក្សារបស់គរុនិស្សិតមានគុណភាព និងប្រសិទ្ធភាព
- គាំទ្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូឧទ្ទេស
- ធានាយន្តការនៃការវាយតម្លៃគ្រូឧទ្ទេសប្រកបដោយប្រសិទ្ធភាព។

ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស នឹងត្រូវបានប្រើប្រាស់ជា៖

- ឯកសារយោងក្នុងការប្រមូលទិន្នន័យលើការអនុវត្តការងារ
- ការណែនាំក្នុងការអភិវឌ្ឍសំណុំឯកសាររបស់គ្រូឧទ្ទេស
- ការណែនាំក្នុងការរៀបចំកម្មវិធីអប់រំ ការអភិវឌ្ឍសមត្ថភាពដល់គ្រូឧទ្ទេស
- ការណែនាំក្នុងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈលើស្តង់ដានានា
- ការណែនាំអភិវឌ្ឍកម្មវិធីនានា ដែលនឹងត្រូវបានតាក់តែងឡើងដើម្បីរៀបអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស

## ៣. គុណសម្បទាគ្រូឧទ្ទេស របស់វិទ្យាស្ថានគរុកោសល្យ

គ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យត្រូវមានគុណសម្បទាពេញលេញក្នុងការអប់រំគ្រូបង្រៀនក្នុងប្រទេសកម្ពុជា។ ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសចង្អុលបង្ហាញពីគុណសម្បទាដែលគ្រូឧទ្ទេសត្រូវមាន ហើយស្តង់ដានេះអាចប្រើជាឧបករណ៍សម្រាប់ស្វ័យពិនិត្យតាមដាន ឬជាឧបករណ៍វាយតម្លៃគ្រូឧទ្ទេសរបស់វិទ្យាស្ថាន។ វិទ្យាស្ថានគរុកោសល្យប្រើប្រាស់ពាក្យ "គុណសម្បទា" សំដៅដល់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសនេះរៀបចំឡើងដើម្បីជួយគ្រូឧទ្ទេសទាំងអស់ ឱ្យមានទំនួលខុសត្រូវលើការអប់រំគ្រូបង្រៀន ទាំងការអប់រំគរុនិស្សិតនៅវិទ្យាស្ថាន និងការ



Khmer Law Association, www.khmerlaw.org

ធ្វើវិក្រឹតការគ្រូបង្រៀននៅតាមសាលារៀនដែលកម្មវិធីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំរបស់គ្រូបង្រៀនចាប់តាំងពីចូលបម្រើការងារអប់រំដំបូង រហូតដល់ឆ្នាំចុងក្រោយនៃអាជីពរបស់ពួកគាត់។

### គ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យគ្រូវ

- មានចំណេះវិជ្ជាបែបវិទ្យាសាស្ត្រ ការយល់ដឹងពីការសិក្សា ការអប់រំ និងការបង្រៀននៅក្នុងសាលារៀន និងនៅវិទ្យាស្ថានគរុកោសល្យ
- មានឧត្តមានុវត្តប្រកបដោយភាពឈ្លាសវៃផ្អែកលើបទពិសោធបង្រៀន
- ផ្សារភ្ជាប់ទំនាក់ទំនងរវាងការអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើខ្លឹមសារមុខវិជ្ជា គរុកោសល្យ និងវិធីសាស្ត្របង្រៀន
- ផ្តោតលើការអភិវឌ្ឍវិជ្ជាជីវៈខ្លួនឯង និងវិជ្ជាជីវៈរបស់គរុនិស្សិ
- ជាគ្រូឧទ្ទេសដែលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ផ្តល់ការលើកទឹកចិត្ត នវានុវត្ត និងមានចំណាប់អារម្មណ៍ចំពោះការអប់រំ
- ស្គាល់តម្លៃខ្លួនឯង មានក្រមសីលធម៌ និងយល់ពីទស្សនៈអប់រំនានា
- ផ្តល់ការអប់រំសីលធម៌ និងសុជីវធម៌ដល់គរុនិស្សិត
- គោរពភាពខុសគ្នានៃវប្បធម៌ សង្គម សាសនា និងជាតិសាសន៍
- ទទួលខុសត្រូវខ្ពស់ចំពោះការងារ សហការល្អជាមួយគ្រូឧទ្ទេសនៃក្រុមមុខវិជ្ជាដទៃក្នុងវិទ្យាស្ថាន និងមានទំនាក់ទំនងល្អជាមួយសាលាសហការ និងសាលាអនុវត្ត
- មានឥរិយាបថចង់ចេះចង់ដឹង សមត្ថភាពស្រាវជ្រាវ និងយល់ដឹងពីការស្រាវជ្រាវក្នុងវិស័យអប់រំ
- មានសមត្ថភាពដឹកនាំគរុនិស្សិតធ្វើការស្រាវជ្រាវអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាពនៅក្នុងវិទ្យាស្ថាន
- មានសមត្ថភាពស្វ័យឆ្លុះបញ្ចាំងជាប្រចាំទៅលើចំណុចខ្លាំង និងចំណុចខ្សោយក្នុងការអនុវត្តការងារជាគ្រូឧទ្ទេស ដើម្បីអភិវឌ្ឍបន្ថែមនូវសមត្ថភាពវិជ្ជាជីវៈខ្លួន
- អនុវត្តតួនាទីភារកិច្ចផ្អែកលើការយល់ដឹងពីការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ និងប្រភពនានា
- ជាបុគ្គលិកអប់រំគំរូ

## ៤. មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូឧទ្ទេស

ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ត្រូវបានកសាងឡើងដោយផ្អែកជាសំខាន់លើចេនាសម្ពន្ធនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនទាំង៤ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក. ២០១៦) រួមបញ្ចូលបន្ថែមនូវស្តង់ដា២ទៀត ដើម្បីឱ្យមានកម្រិតខ្ពស់ជាងគ្រូបង្រៀនទូទៅ។ ជារួម ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសសម្រាប់វិទ្យាស្ថានគរុកោសល្យមានមូលដ្ឋានគ្រឹះ សម្រាប់ការប្រតិបត្តិវិជ្ជាជីវៈជាគ្រូឧទ្ទេស សរុប៦ស្តង់ដា។



Khmer Law Association, www.khmerlaw.org

មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូឧទ្ទេសជាមូលដ្ឋាននៃគុណផលស្តង់ដារបស់គ្រូឧទ្ទេស។ ការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូឧទ្ទេសមានមូលដ្ឋានគ្រឹះសំខាន់ៗ៣ៈ

- អភិវឌ្ឍសមត្ថភាពគរុនិស្សិតលើខ្លឹមសារមុខវិជ្ជា និងរបៀបរៀនរបស់គរុនិស្សិត
- អភិវឌ្ឍសមត្ថភាពគរុនិស្សិតលើគរុកោសល្យ និងវិធីសាស្ត្របង្រៀន
- អភិវឌ្ឍវិជ្ជាជីវៈគ្រូឧទ្ទេសខ្លួនឯង

(Koster & Dengerink, 2001; Snoek, Swennen & van der Valk, 2006)

## ៥. ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស

ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស នៃវិទ្យាស្ថានគរុកោសល្យបង្ហាញពីលក្ខណៈវិជ្ជាជីវៈយ៉ាងច្បាស់លាស់ ដែលជាបទដ្ឋានគោលសម្រាប់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូឧទ្ទេស។ ការពណ៌នានៅក្នុងស្តង់ដានេះ ផ្តោតជាសំខាន់លើ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលគ្រូឧទ្ទេសម្នាក់ៗត្រូវមានជាចាំបាច់។ លើសពីនេះ ស្តង់ដាទាំងនេះអាចជាត្រីវិស័យក្នុងការបំពេញតួនាទីភារកិច្ចរបស់គ្រូឧទ្ទេសជាបុគ្គល ឬការសហប្រតិបត្តិការជាក្រុម (ក្រុមវិជ្ជាជីវៈភាវូបនីយកម្ម, team professionalization) ។ តាមរយៈស្តង់ដាវិជ្ជាជីៈនេះ គ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរកឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវអភិវឌ្ឍសមត្ថភាពបន្ថែម ដើម្បីបំពេញកម្រិតស្តង់ដាដែលខ្លួននៅខ្វះខាត និងត្រូវបានប្រើសម្រាប់ការវាយតម្លៃពីលទ្ធផលសម្រេចបាន សម្រាប់គន្លងអាជីពអប់រំសម្រាប់គ្រូឧទ្ទេស។

ស្តង់ដានីមួយៗនៃស្តង់ដាទាំង៦របស់គ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្យ មានសេចក្តីពណ៌នាច្បាស់លាស់ រួមជាមួយនឹងសូចនាករ និងភស្តុតាងបញ្ជាក់ពីផលសម្រេចដែលគ្រូឧទ្ទេសកសាងបានឆ្លើយតបទៅនឹងសូចនាករនីមួយៗ យ៉ាងជាក់លាក់បំផុត។ (សូមមើលឧបសម្ព័ន្ធ)




*រូបភាពទី១៖ ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស*



Khmer Law Association, www.khmerlaw.org

### ស្តង់ដាទី១៖ ចំណេះដឹងវិជ្ជាជីវៈ

គ្រូឧទ្ទេសដែលបម្រើការងារនៅវិទ្យាស្ថានគរុកោសល្យត្រូវមានចំណេះដឹងច្បាស់លាស់អំពី តម្រូវការនៃការសិក្សា សារតានៃការសិក្សា និងឥរិយាបថរបស់គរុនិស្សិតម្នាក់ៗរបស់ពួកគេ។ គ្រូឧទ្ទេសត្រូវយល់ដឹងអំពីចំណេះដឹង និងសមត្ថភាពខុសៗគ្នារបស់សិស្សផងដែរ។ លើសពីនេះ គ្រូឧទ្ទេសចាំបាច់ត្រូវយល់ដឹងពីស្ថានភាពគ្រួសារ និងកត្តាពាក់ព័ន្ធនានា ដែលជះឥទ្ធិពលដល់ការសិក្សារបស់គរុនិស្សិតដូចជាកត្តាយេនឌ័រ ពិការភាព ជនជាតិភាគតិច។ល។ ព្រមទាំងដឹងពីវិធីដោះស្រាយបញ្ហាទាំងនោះផងដែរ។ បន្ថែមពីនេះ គ្រូឧទ្ទេសត្រូវយល់ដឹងឱ្យបានច្បាស់លាស់ពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ គោលដៅអប់រំអន្តរជាតិ និងគោលបំណងនៃការអប់រំនៅចំណេះទូទៅ។

សមត្ថភាពរបស់គ្រូឧទ្ទេសនៅក្នុងស្តង់ដានេះរួមមាន៖

- ចំណេះដឹងអំពីគរុនិស្សិត
- ចំណេះដឹងលើមុខវិជ្ជាឯកទេស
- ចំណេះដឹងលើវិធីរៀនរបស់គរុនិស្សិត
- ចំណេះដឹងលើបរិបទអប់រំ

### ស្តង់ដាទី២៖ ការប្រតិបត្តិវិជ្ជាជីវៈ

គ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្យត្រូវរៀបចំឱ្យមានកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាពដែលផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សា និងការប្រើប្រាស់សម្ភារៈសិក្សាឱ្យបានសមស្របតាមខ្លឹមសារមេរៀន។ គ្រូឧទ្ទេសត្រូវត្រូវមានសមត្ថភាពប្រើប្រាស់វិធីសាស្ត្រ និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិតសំបូរបែប ដោយផ្សារភ្ជាប់ជាមួយនឹងតម្រូវការមូលដ្ឋាន និងជំនាញចាំបាច់របស់គរុនិស្សិតម្នាក់ៗ។ គ្រូឧទ្ទេសត្រូវផ្តល់ព័ត៌មានត្រឡប់ដល់គរុនិស្សិត មាតាបិតា និងអាណាព្យាបាលរបស់គរុនិស្សតអំពីវឌ្ឍនភាព នៃការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាគ្រូបង្រៀន រួមទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់គរុនិស្សិត។

សមត្ថភាពរបស់គ្រូឧទ្ទេសនៅក្នុងស្តង់ដានេះរួមមាន៖

- ការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត
- ការគ្រប់គ្រងបរិស្ថានសិក្សា
- វិធីសាស្ត្របង្រៀន
- កិច្ចសហការ

### ស្តង់ដាទី៣៖ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

គ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្យ ទាមទារឱ្យមានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធ ដោយឆ្លុះបញ្ចាំង និងកែលម្អការអនុវត្តរបស់ខ្លួនជាលំដាប់ ដើម្បីលើកទឹកចិត្ត និងធានាពីភាពជោគជ័យនៃការសិក្សារបស់គរុនិស្សិត ។

ក្នុងន័យនេះ គ្រូឧទ្ទេសត្រូវបង្កើតផែនការសម្រាប់ជំរុញស្វ័យសិក្សា និងការវាយតម្លៃការបង្រៀននិងរៀនរបស់ខ្លួនឱ្យបានទៀងទាត់ និងផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំឆ្នាំ។ បន្ថែមពីលើសមត្ថភាពលើមុខវិជ្ជាឯកទ្ទេសបង្រៀន និងវិធីសាស្ត្របង្រៀន គ្រូឧទ្ទេសត្រូវអភិវឌ្ឍជំនាញបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រើប្រាស់ក្នុងការបង្រៀន ភាសាបរទេស និងជំនាញទំនាក់ទំនងជាមួយគរុនិស្សិត មាតាបិតា  គ្រូឧទ្ទេសផ្សេងៗ និងសហគមន៍គ្រូបង្រៀនផ្សេងទៀត។

សកម្មភាពគោលក្នុងការអភិវឌ្ឍសមត្ថភាពរបស់គ្រូឧទ្ទេសរួមមាន៖

- ស្វ័យសិក្សា និងការឆ្លុះបញ្ចាំង
- ការសង្កេតដោយហ្មត់ចត់លើយុទ្ធវិធីនានា និង
- ការពិនិត្យតាមដាន សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ

សមត្ថភាពរបស់គ្រូឧទ្ទេសនៅក្នុងស្តង់ដានេះរួមមាន៖

- ស្វ័យសិក្សា និងការឆ្លុះបញ្ចាំង
- ការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ការចូលរួមជាសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ

## ស្តង់ដាទី៤៖ សីលធម៌វិជ្ជាជីវៈ

សីលធម៌វិជ្ជាជីវៈ ជាផ្នែកមួយសំខាន់ ដែលទាក់ទងទៅគ្រប់ផ្នែកនានានៃវិជ្ជាជីវៈគ្រូឧទ្ទេស។ សីលធម៌វិជ្ជាជីវៈមានរួមបញ្ចូលទាំងការប្តេជ្ញាចិត្តក្នុងការបង្រៀនគរុនិស្សិតឱ្យបានល្អប្រសើរ ការប្រើប្រាស់មនសិការវិជ្ជាជីវៈក្នុងការបំពេញកិច្ចការប្រកបដោយភាពឈ្លាសវៃ និងមានចំណេះដឹងគ្រប់គ្រាន់ស្របតាមក្រមសីលធម៌ នៃច្បាប់អប់រំរបស់ក្រសួងអប់រំ  យុវជន និងកីឡា។

គ្រូឧទ្ទេសត្រូវធ្វើជាគំរូល្អដល់គរុនិស្សិតទាំងជីវិតជាគ្រូបង្រៀន និងការសិក្សា ជាពិសេសការយល់ដឹងពីរបៀបលើកទឹកចិត្ត ស្មារតីក្រុម ការប្តេជ្ញាចិត្ត និងការចូលរួមចែករំលែកដល់សហគមន៍។

សមត្ថភាពរបស់គ្រូឧទ្ទេសនៅក្នុងស្តង់ដានេះរួមមាន៖

- ការយកចិត្តទុកដាក់ចំពោះគរុនិស្សិត
- ការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវលើវិជ្ជាជីវៈគ្រូបង្រៀន
- ការធ្វើជាគំរូវិជ្ជមាននៃចរិយាធម៌
- សមត្ថភាពលើកកម្ពស់វប្បធម៌ និងយុត្តិធម៌ក្នុងការអប់រំ
- ការវាយតម្លៃលទ្ធផលការសិក្សារបស់គរុនិស្សិត



Khmer Law Association, www.khmerlaw.org

## ស្តង់ដាទី៥៖ ការស្រាវជ្រាវអប់រំ

គ្រូឧទ្ទេសដែលប្រកបដោយជំនាញវិជ្ជាជីវៈ មិនត្រឹមតែអាចបង្រៀនគរុនិស្សិតប្រកបដោយគុណភាព និង ប្រសិទ្ធភាពប៉ុណ្ណោះទេ តែត្រូវធ្វើការសិក្សាស្រាវជ្រាវអប់រំ( ការស្រាវជ្រាវប្រតិបត្តិ )ផងដែរ ដើម្បីចូលរួមចែករំលែកឧត្តមានុវត្តន៍ដល់សហគមន៍គ្រូបង្រៀន និងដើម្បីចូលរួមជានាឱ្យបាននូវគុណភាពអប់រំកម្រិតខ្ពស់នៅក្នុងប្រទេសកម្ពុជា ក្នុងនាមជាវិទ្យាស្ថានអប់រំគ្រូបង្រៀនដែលផ្តល់កម្មវិធីកម្រិតឧត្តមសិក្សា។

គ្រូឧទ្ទេសត្រូវសម្រេចកិច្ចការស្រាវជ្រាវរបស់ខ្លួន ដោយធ្វើការអង្កេត ប្រមូលទិន្នន័យ និងវិភាគបានហ្មត់ចត់ លើការអភិវឌ្ឍថ្មីនៃបរិបទអប់រំ ការបង្រៀននិងរៀន និងតាមទ្រឹស្តីផ្សេងៗ។ គ្រូឧទ្ទេសត្រូវប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន និងលទ្ធផលនៃការស្រាវជ្រាវនានាដទៃទៀតជាប្រយោជន៍ ដើម្បីអភិវឌ្ឍការគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនក្នុងថ្នាក់របស់ខ្លួន។

ក្នុងន័យនេះ គ្រូឧទ្ទេសត្រូវយល់ដឹងពីវិធីសាស្ត្រស្រាវជ្រាវអប់រំ( ការស្រាវជ្រាវប្រតិបត្តិ ) ជំនាញវិភាគ ជំនាញសរសេររបាយការណ៍ស្រាវជ្រាវ និងធ្វើការបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃកិច្ចការស្រាវជ្រាវរបស់ខ្លួនក្នុងកាលិកបត្រ ឬព្រឹត្តិបត្រស្រាវជ្រាវ ធ្វើបទបង្ហាញក្នុងសន្និសីទអប់រំ។ លើសពីនេះ គ្រូឧទ្ទេសត្រូវបង្រៀន និងជួយដឹកនាំគាំទ្រគរុនិស្សិតរបស់ខ្លួនឱ្យមានសមត្ថភាពធ្វើការសិក្សាស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់ផងដែរ។

សមត្ថភាពរបស់គ្រូឧទ្ទេសនៅក្នុងស្តង់ដានេះរួមមាន ៖

- ចំណេះដឹង និងជំនាញស្រាវជ្រាវអប់រំ
- ការអនុវត្តការស្រាវជ្រាវអប់រំ

## ស្តង់ដាទី៦៖ ការអភិវឌ្ឍកម្មវិធីអប់រំ

គ្រូឧទ្ទេសបម្រើការនៅវិទ្យាស្ថានគរុកោសល្យ ត្រូវមានសមត្ថភាពក្នុងភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃកម្មវិធីអប់រំគ្រូបង្រៀន ដោយផ្អែកលើទ្រឹស្តីមូលដ្ឋាន លទ្ធផលរបស់អ្នកស្រាវជ្រាវ និងឧត្តមានុវត្តន៍នានា ដែលពាក់ព័ន្ធ។

មូលដ្ឋានគ្រឹះនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូឧទ្ទេសសម្រាប់ស្តង់ដានេះគឺត្រូវអភិវឌ្ឍ និងអនុវត្តកម្មវិធីអប់រំគ្រូបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ និងជួយដល់គ្រូឧទ្ទេសដែលទើបតែចេញបង្រៀនថ្មី ឱ្យអាចអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងអំឡុងពេល និងបន្ទាប់ពីចាប់ផ្តើមអាជីពវិជ្ជាជីវៈ។

សមត្ថភាពរបស់គ្រូឧទ្ទេសនៅក្នុងស្តង់ដានេះរួមមាន៖

- ការអភិវឌ្ឍ និងការកែលម្អកម្មវិធីអប់រំ
- ការវាយតម្លៃកម្មវិធីអប់រំ

## ៦. យន្តការនៃការវាយតម្លៃលទ្ធផលអនុវត្តស្តង់ដា

គុណផលរបស់គ្រូឧទ្ទេសនឹងត្រូវវាយតម្លៃរៀងរាល់ឆ្នាំ ដោយផ្អែកលើស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ដោយអនុវត្តតាមវដ្តនៃការវាយតម្លៃការងារផ្អែកលើលទ្ធផល (Result-Oriented-Work (ROW) Assessment)។

## ៦.១. ការវាយតម្លៃការងារផ្អែកលើលទ្ធផល

ការវាយតម្លៃការងារផ្អែកលើលទ្ធផល ត្រូវបានអនុវត្តសម្រាប់ការវាយតម្លៃគ្រូឧទ្ទេសរបស់វិទ្យាស្ថានគរុកោសល្យប្រចាំឆ្នាំ នៅតាមកម្រិតឋានុក្រមគ្រប់គ្រងនីមួយ នៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់វិទ្យាស្ថាន។ ក្នុងពេលដំណើរវាយតម្លៃ ផែនការ គោលបំណង ការអនុវត្ត និងលទ្ធផលការងារនឹងត្រូវពិនិត្យវាយតម្លៃ ធៀបនឹងផែនការសកម្មភាព និងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសម្នាក់ៗដែលខ្លួនបានបង្កើតនៅដើមឆ្នាំសិក្សា ឆ្លើយតបនឹងតម្រូវការស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសរបស់វិទ្យាស្ថានគរុកោសល្យ។

### ៦.១.១. គោលដៅនៃការវាយតម្លៃការងារផ្អែកលើលទ្ធផល

វាយតម្លៃការងារផ្អែកលើលទ្ធផលមានគោលដៅដូចខាងក្រោម៖

- បង្កើតកិច្ចផែនការ (កិច្ចព្រមព្រៀង) នៅដើមឆ្នាំសិក្សាពីលទ្ធផលដែលគ្រូឧទ្ទេសម្នាក់ៗត្រូវសម្រេចឱ្យបាននៅចុងឆ្នាំសិក្សា
- ពិនិត្យតាមដានលើវឌ្ឍនភាពនៃការអនុវត្តផែនការ (កិច្ចព្រមព្រៀង) នៅពាក់កណ្តាលឆ្នាំសិក្សា
- វាយតម្លៃការអនុវត្តផែនការដោយផ្អែកលើលទ្ធផលដែលបានសម្រេចនៅចុងឆ្នាំសិក្សា

### ៦.១.២. វដ្តនៃការវាយតម្លៃការងារផ្អែកលើលទ្ធផល (ROW Cycle)




*រូបភាព២៖ វដ្តនៃការវាយតម្លៃការងារផ្អែកលើលទ្ធផល*

ក្នុងឆ្នាំសិក្សានីមួយៗ មានការវាយតម្លៃការងារផ្អែកលើលទ្ធផលចំនួន៣ដងជាផ្លូវការរវាងគ្រូឧទ្ទេសជាមួយនឹងគណៈគ្រប់គ្រងតាមលំដាប់ខ្សែឋានានុក្រម (Line Mangement) នៃរចនាសម្ព័ន្ធរបស់វិទ្យាស្ថាន រួមមាននាយកនាយករង/នាយិការង ប្រធានការិយាល័យ/ដេប៉ាតឺម៉ង់។ ការពិនិត្យតាមដាន និងវាយតម្លៃតាមខ្សែឋានានុក្រម ត្រូវបានកំណត់អនុវត្តដូចខាងក្រោម៖

- អនុប្រធានប្រធានការិយាល័យ/ដេប៉ាតឺម៉ង់ ត្រូវទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់មន្ត្រី/គ្រូឧទ្ទេសទាំងអស់នៅក្នុងបន្ទុករបស់ខ្លួន
- ប្រធានការិយាល័យ/ដេប៉ាតឺម៉ង់ ត្រូវទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់អនុប្រធានការិយាល័យ/ដេប៉ាតឺម៉ង់ទាំងអស់នៅក្នុងបន្ទុករបស់ខ្លួន
- ព្រឹទ្ធបុរសរងត្រូវទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់ប្រធាដេប៉ាតឺម៉ង់ទាំងអស់នៅក្នុងបន្ទុករបស់ខ្លួន
- ព្រឹទ្ធបុរសត្រូវទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់ព្រឹទ្ធបុរសរងទាំងអស់នៅក្នុងបន្ទុករបស់ខ្លួន
- នាយករង/នាយិការងត្រូវទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់ប្រធានការិយាល័យ ឬព្រឹទ្ធបុរសទាំងអស់នៅក្នុងបន្ទុករបស់ខ្លួន
- នាយកវិទ្យាស្ថានគរុកោសល្យទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់នាយករង/នាយិការងទាំងអស់
- ប្រធានក្រុមប្រឹក្សាបច្ចេកទេសទទួលបន្ទុក ពិនិត្យ តាមដាន និងវាយតម្លៃការងារផ្អែកលើលទ្ធផលរបស់នាយកវិទ្យាស្ថាន។

**ដំណាក់កាលទី១៖ ការធ្វើផែនការ (ចុះកិច្ចព្រមព្រៀងដើមឆ្នាំ)**

គ្រូឧទ្ទេស ឬមន្ត្រីអប់រំត្រូវរៀបចំផែនការ និងកំណត់លទ្ធផលការងាររំពឹងទុកដែលនឹងត្រូវសម្រេចឱ្យបានដំណាច់ឆ្នាំសិក្សា។ ផែនការនេះ ចាត់ទុកជាកិច្ចព្រមព្រៀងរបស់គ្រូឧទ្ទេស ឬមន្ត្រីអប់រំ ដោយឆ្លងកាត់ការពិនិត្យ ពិភាក្សាផ្តល់យោបល់ពីប្រធានតាមឋានានុក្រមផ្ទាល់ និងចុងក្រោយត្រូវដាក់ជូននាយកវិទ្យាស្ថានចុះហត្ថលេខាឯកភាព។ ផែនការ ដែលជាកិច្ចព្រមព្រៀងដើមឆ្នាំនេះ នឹងត្រូវរក្សាទុកក្នុងសំណុំឯកសារអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូឧទ្ទេស ឬមន្ត្រីអប់រំផ្ទាល់ខ្លួន នៅតាមការិយាល័យ/ដេប៉ាតឺម៉ង់នីមួយៗ។

**ដំណាក់កាលទី២៖ ការត្រួតពិនិត្យការអនុវត្តការងារ**

នៅពាក់កណ្ដាលឆ្នាំសិក្សា មន្ត្រីអប់រំ ឬគ្រូឧទ្ទេសត្រូវធ្វើរបាយការណ៍ពីវឌ្ឍនភាព (ផលសម្រេច និងបញ្ហាប្រឈម) នៃការអនុវត្តផែនការដែលជាកិច្ចព្រមព្រៀងកាលពីដើមឆ្នាំ និងដាក់ជូនប្រធានតាមឋានានុក្រមដើម្បីពិនិត្យ តាមដាន និងផ្ដល់អនុសាសន៍ធ្វើយ៉ាងណាឱ្យសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុកកាលពីដើមឆ្នាំទាំងនោះ។



Khmer Law Association, www.khmerlaw.org

**ដំណាក់កាលទី៣៖ ការវាយតម្លៃចុងឆ្នាំ**

នៅចុងបញ្ចប់នៃឆ្នាំសិក្សានីមួយៗ គ្រូឧទ្ទេសត្រូវធ្វើរបាយការណ៍លទ្ធផលការងារដែលសម្រេចបាន ដើម្បីដាក់ជូនគណៈគ្រប់គ្រង និងវាយតម្លៃ។ គណៈគ្រប់គ្រងតាមខ្សែឋានានុក្រមត្រូវកំណត់ពេលវេលាដាក់លាក់ណាមួយ ដើម្បីជួបពិភាក្សា និងផ្តល់លទ្ធផលនៃការវាយតម្លៃ ដល់បុគ្គលិកអប់រំក្រោមឱវាទរបស់ខ្លួន។ គ្រូឧទ្ទេសប្រើប្រាស់លទ្ធផលនៃការវាយតម្លៃចុងក្រោយ ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តការងារ និងលើកទិសដៅការងារសម្រាប់រៀបចំផែនការនៅឆ្នាំសិក្សាបន្ទាប់ទៀត។

## ៦.២. វិធីសាស្ត្រនៃការវាយតម្លៃការងារផ្អែកលើលទ្ធផល

ការវាយតម្លៃការងារផ្អែកលើលទ្ធផល ត្រូវធ្វើឡើងតាមរយៈមធ្យោបាយជាច្រើនដូចជាការពិនិត្យសំណុំឯកសាររបាយការណ៍ស្វ័យឆ្លុះបញ្ចាំង ការសង្កេតការបង្រៀន ការវាយតម្លៃពីគ្រូឧទ្ទេស/មន្ត្រីអប់រំជាសហការី និងការវាយតម្លៃដោយគរុនិស្សិត។

### ៦.២.១. ការពិនិត្យសំណុំឯកសារគ្រូឧទ្ទេស

ក្នុងអំឡុងពេលអនុវត្តអាជីពវិជ្ជាជីវៈ គ្រូឧទ្ទេសត្រូវបង្កើត និងបំពេញសំណុំឯកសារវិជ្ជាជីវៈរួមមាន៖

- ប្រវត្តិរូបសង្ខេបនិងព័ត៌មានផ្ទាល់ខ្លួនដូចជា៖ ព្រឹត្តិបត្រពិន្ទុ ឯកសារវិជ្ជាជីវៈគ្រូបង្រៀន បណ្ណសរសើរមេដាយ ស្នាដៃស្រាវជ្រាវ កំណត់ត្រាបណ្តុះបណ្តាល និងវិញ្ញាបនបត្រអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- របាយការណ៍ស្វ័យឆ្លុះបញ្ចាំង(ស្វ័យវាយតម្លៃ)
- ទស្សនៈវិជ្ជាផ្ទាល់ខ្លួនលើការអប់រំ
- កិច្ចព្រមព្រៀងការអនុវត្តការងារប្រចាំឆ្នាំ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារ
- កម្មវិធីសិក្សាលម្អិតតាមមុខវិជ្ជា កិច្ចតែងការបង្រៀន និងសម្ភារៈឧបទេស
- របាយការណ៍ស្តីពីការសង្កេតថ្នាក់រៀនរបស់គ្រូឧទ្ទេស និង
- ឯកសារពាក់ព័ន្ធផ្សេងៗ

### ៦.២.២. របាយការណ៍ស្វ័យឆ្លុះបញ្ចាំង (ស្វ័យវាយតម្លៃ)

គ្រូឧទ្ទេសត្រូវវាយតម្លៃការអនុវត្តការងាររបស់ខ្លួនតាមរយៈការធ្វើស្វ័យឆ្លុះបញ្ចាំង។ ក្នុងការធ្វើស្វ័យឆ្លុះបញ្ចាំង គ្រូឧទ្ទេសត្រូវពិនិត្យទៅលើ គោលបំណង/គោលដៅ និងផែនការប្រចាំឆ្នាំដែលបានរៀបចំនៅដើមឆ្នាំសិក្សា។ ការឆ្លុះបញ្ចាំងមានបីជំហានដូចជា ពណ៌នាពីការអនុវត្តការងារ វិភាគលទ្ធផលទាំងវិជ្ជមាននិងអវិជ្ជមាន និងសំយោគលទ្ធផលដែលរកឃើញដើម្បីធ្វើផែនការបន្ត។

### ៦.២.៣. ការវាយតម្លៃដោយគរុនិស្សិត

ការវាយតម្លៃដោយគរុនិស្សិតជាផ្នែកមួយនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់គ្រូឧទ្ទេសដែលធ្វើឡើងដោយការិយាល័យធានាគុណភាពផ្ទៃក្នុង។ គ្រូឧទ្ទេសនឹងត្រូវវាយតម្លៃដោយគរុនិស្សិតតាមរយៈ



Khmer Law Association, www.khmerlaw.org

ការបំពេញកម្រងសំណួរស្ទង់មតិក្រោយពីបញ្ចប់មុខវិជ្ជាសិក្សានីមួយៗ។ លទ្ធផលនៃការវាយតម្លៃនឹងបញ្ជូនទៅគណៈគ្រប់គ្រងដេប៉ាតឺម៉ង់ ដើម្បីវាយតម្លៃការអនុវត្តការងាររបស់គ្រូឧទ្ទេសជាលក្ខណៈបុគ្គលក្រោមការដឹកនាំពីនាយករង/នាយិការងទទួលបន្ទុក។

## ៦.៣. សូចនាករ និងភស្តុតាង

ស្តង់ដាទាំង៦នៃស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសមានសូចនាករ និងភស្តុតាងជាក់លាក់។ ភស្តុតាងដែលបានរៀបរាប់នៅតាមស្តង់ដានីមួយៗបញ្ជាក់នូវកម្រិតសម្រេចបាននៃសូចនាករ និងស្តង់ដា។ ភស្តុតាងមានដូចជា ព្រឹត្តបត្រស្វ័យវាយតម្លៃ សំណុំឯកសារវិជ្ជាជីវៈគ្រូឧទ្ទេស លទ្ធផលវាយតម្លៃរបស់គរុសិស្ស និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

## ៦.៤. កម្រិតនៃការវាយតម្លៃ

ការវាយតម្លៃការអនុវត្តការងាររបស់គ្រូឧទ្ទេសនឹងត្រូវបែងចែកជា៣(បី)កម្រិត៖

- **កម្រិត១៖ មិនគ្រប់គ្រាន់** => ប្រសិនបើលទ្ធផលចុងក្រោយមិនបានសម្រេចតាមគោលដៅរំពឹងទុក
- **កម្រិត២៖ ល្អ** => ប្រសិនបើលទ្ធផលចុងក្រោយសម្រេចបានតាមគោលដៅរំពឹងទុក
- **កម្រិត៣៖ ល្អប្រសើរ** => ប្រសិនបើលទ្ធផលចុងក្រោយសម្រេចបានលើសពីគោលដៅរំពឹងទុក

គ្រូឧទ្ទេសដែលអនុវត្តការងារបានល្អប្រសើរ មានការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវខ្ពស់ស្របតាមតម្រូវការរបស់វិទ្យាស្ថាន អាចចាត់ទុកថាជាគ្រូឧទ្ទេសឆ្នើមប្រចាំឆ្នាំសិក្សា។ លលទ្ធផលនៃការវាយតម្លៃនេះ និងត្រូវប្រើប្រាស់ផងដែរសម្រាប់ការវាយតម្លៃដំឡើងឋានៈគ្រូឧទ្ទេស និងការផ្តល់អាទិភាពផ្សេងៗទៀត។



Khmer Law Association, www.khmerlaw.org

# ឯកសារយោង

ATE (Association of Teacher Educators), (2013) Standards for Teacher Educators, retrieved November 22, 2019.

Darling-Hammond, L., & Bransford, J. (2005). Preparing teachers for a changing world: What teachers should learn and be able to do. San Francisco, CA: Jossey-Bass.

Gay, G. (2005). A synthesis of scholarship in multicultural education. Naperville, IL: North Central Regional Educational Laboratory.

Ingvarson, L. (1998) Professional development as the pursuit of professional standards: the standards-based professional development system. *Teaching and Teacher Education, 14*(1),127-140.

Koster, B. & Dengerink, J. (2001). Towards a Professional Standard for Dutch Teacher Educators. *European Journal of Teacher Education*, *24*(3), 343-354.

Ministry of Education, Youth and Sport. (2010). Teacher Professional Standards. Phnom Penh: MoEYS (Teacher Training Development).

Murray, J., Male, T. (2005). Becoming a teacher educator: evidence from the field. *Teaching and Teacher Education, 21*(2), 125-142.

Seameo Innotech Reginal Education Program (SIREP). (2010). *Teaching Competency Standards in Southeast Asian Countries*. Philippines: SIREP.

Snoek, M., Swennen, A. & Valk, J. de (eds) (2006) Teachers and their Educators - Standards for Development; Proceedings of the 30th Annual Conference ATEE, Amsterdam 22-26 October 2005. Amsterdam, Hogeschool van Amsterdam.

Universitas Pendidikan. (2017). The Proposed Teacher Education Standards and Teacher Education Qualification Framework for QAA-TEIA (quality assurance agencies for teacher education in ASEAN). Indonesia: Universitas Pendidikan.

Velon NL, (2012) Beroepsstandard Lerarenopleiders, Eindhoven, VELON.



Khmer Law Association, www.khmerlaw.org

## ឧបសម្ព័ន្ធ១៖ សមាសភាពស្តង់ដាវិជ្ជាជីវៈគ្រូឧត្តមទេស វិទ្យាស្ថានគរុកោសល្យ

**១ .ចំណេះដឹងវិជ្ជាជីវៈ**

១.១. ចំណេះដឹងអំពីគរុនិស្សិត

១.២. ចំណេះដឹងលើមុខវិជ្ជាឯកទេស

១.៣. ចំណេះដឹងលើវិធីរៀនរបស់គរុនិស្សិត

១.៤. ចំណេះដឹងលើបរិបទអប់រំ

**២. ការប្រតិបត្តិវិជ្ជាជីវៈ**

២.១. ការការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត

២.២. ការគ្រប់គ្រងបរិស្ថានសិក្សា

២.៣. វិធីសាស្រ្តបង្រៀន

២.៤. កិច្ចសហការ

**៣. ការអភិវឌ្ឍវិជ្ជាជីវៈ**

៣.១. ស្វ័យសិក្សា និងការឆ្លុះបញ្ចាំង

៣.២. ការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

៣.៣. ការចូលរួមជាសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ

**៤. សីលធម៌វិជ្ជាជីវៈ**

៤.១. ការយកចិត្តទុកដាក់ចំពោះគរុនិស្សិត

៤.២. ការប្តេជ្ញាចិត្ត និងទំនួលខុសត្រូវលើវិជ្ជាជីវៈគ្រូបង្រៀន

៤.៣. ការធ្វើជាគំរូវិជ្ជមាននៃចរិយាធម៌

៤.៤. សមត្ថភាពលើកកម្ពស់វប្បធម៌ និងយុត្តិធម៌ក្នុងការអប់រំ

៤.៥. ការវាយតម្លៃលទ្ធផលការសិក្សារបស់គរុនិស្សិត

**៥. ការស្រាវជ្រាវអប់រំ**

៥.១. ចំណេះ និងជំនាញស្រាវជ្រាវអប់រំ

៥.២. ការអនុវត្តការស្រាវជ្រាវអប់រំ

**៦. ការអភិវឌ្ឍកម្មវិធីអប់រំ**

៦.១. ការអភិវឌ្ឍ និងការកែលម្អកម្មវិធីអប់រំ

៦.២. ការវាយតម្លៃកម្មវិធីអប់រំ



Khmer Law Association, www.khmerlaw.org

## ឧបសម្ពន្ធ២៖ សូចនាករ និងភស្តុតាង តាមស្តង់ដានីមួយៗ

| ស្តង់ដាទី១៖ ចំណេះដឹងវិជ្ជាជីវៈ | សូចនាករ | ភស្តុតាងសំខាន់ៗ |
|---|---|---|
| ១.១. ចំណេះដឹងអំពីគរុនិស្សិត | ១.១.១. យល់ដឹងពីឥទ្ធិពលយេនឌ័រ សង្គមសេដ្ឋកិច្ច ពិការភាព អភិភាព លើការសិក្សារបស់គរុនិស្សិត និងដំណោះស្រាយ | -កម្មវិធីសិក្សាលម្អិត<br>-កិច្ចតែងការបង្រៀន<br>-របាយការណ៍/លិខិតឧទ្ទេសនាមនៃការចូលរួមសិក្ខាសាលាពាក់ព័ន្ធនឹងយេនឌ័រ សង្គមសេដ្ឋកិច្ច ពិការភាព និងអភិភាពជុំវិញការអប់រំ<br>-បទបង្ហាញ រួមមានស្លាយមេរៀន វីដេអូ និង/ឬសំឡេង<br>-របាយការណ៍វាយតម្លៃគ្រូឧទ្ទេសដោយគរុនិស្សិត<br>-របាយការណ៍ស្វ័យវាយតម្លៃរបស់គ្រូឧទ្ទេស<br>-សំណុំឯកសាររបស់គ្រូឧទ្ទេស<br>-សំណុំឯកសាររបស់គរុនិស្សិត<br>-របាយការណ៍សង្កេតថ្នាក់រៀន<br>-របាយការណ៍សេវាសុខុមាលភាពគរុនិស្សិត |
| | ១.១.២.យល់ដឹងពីតម្រូវការក្នុងការសិក្សា សមត្ថភាព ប្រវត្តិនៃការសិក្សា និងឥរិយាបថសិក្សារបស់គរុនិស្សិត | |
| | ១.១.៣.យល់ដឹងពីរបៀប និងសមត្ថភាពសិក្សារបស់គរុនិស្សិត | |
| | ១.១.៤.យល់ដឹងពីឥទ្ធិពលនៃពិការភាព និងជនជាតិភាគតិចចំពោះការសិក្សារបស់គរុនិស្សិត | |
| | ១.១.៥.យល់ដឹងពីវិធីនាំឱ្យមានសមភាពយេនឌ័រ និងក្រុមជនជាតិភាគតិច | |
| | ១.១.៦.ផ្តល់ការយកចិត្តទុកដាក់ និងឱកាសប្រើប្រាស់ធនធានដល់គរុនិស្សិតស្មើៗគ្នា | |
| | ១.១.៧. បង្ហាញនូវចំណាប់អារម្មណ៍លើការសិក្សារបស់គរុនិស្សិត | |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| ១.២. ចំណេះដឹងលើមុខវិជ្ជាឯកទេស | ១.២.១.មានគុណវុឌ្ឍិស្របនឹងមុខវិជ្ជាឯកទេស | - សញ្ញាបត្រ និងព្រឹត្តបត្រពិន្ទុ( បរិញ្ញាបត្រជាន់ខ្ពស់ បណ្ឌិត )<br>- កម្មវិធីសិក្សាលម្អិត<br>- កិច្ចតែងការបង្រៀន<br>- បទបង្ហាញវីដេអូ និងសំឡេង<br>- របាយការណ៍ស្វ័យវាយតម្លៃ<br>- របាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីអប់រំ<br>- របាយការណ៍/លិខិតឧទ្ទេសនាម ឬ វិញ្ញាបនបត្រចូលរួមសិក្ខាសាលា |
| | ១.២.២.មានចំណេះដឹងច្បាស់លាស់លើមុខវិជ្ជាឯកទេស | |
| | ១.២.៣.មានចំណេះដឹងផ្នែកគោលនយោបាយអប់រំជាតិ គោលដៅ និងគោលបំណងនៃការអប់រំចំណេះទូទៅ | |
| | ១.២.៤.មានកិច្ចតែងការបង្រៀនបានច្បាស់លាស់ | |
| | ១.២.៥. មានសមត្ថភាពពន្យល់មេរៀនតាមខ្លឹមសារកម្មវិធីសិក្សាបានល្អ | |
| | ១.២.៦.យល់ពីរបៀបផ្សារភ្ជាប់រវាងមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ដែលគរុនិស្សិតអាចយកទៅអនុវត្តបាន | |
| | ១.២.៧. បានអានអត្ថបទស្រាវជ្រាវថ្មីៗពាក់ព័ន្ធនឹងមុខវិជ្ជាឯកទេស | |
| | ១.២.៨.ប្រើប្រាស់ព័ត៌មានថ្មីៗ និងច្បាស់លាស់ក្នុងការបង្រៀន | |
| | ១.២.៩. យល់ដឹងច្បាស់លាស់ពីបញ្ញត្តិ ទ្រឹស្តី និងការអនុវត្តក្នុងមុខវិជ្ជាឯកទេស | |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| ១.៣. ចំណេះដឹងលើវិធីរៀនរបស់គរុនិស្សិត | ១.៣.១. យល់ដឹងពីបរិបទអប់រំនៃថ្នាក់រៀននីមួយៗ | - លទ្ធផលសិក្សារបស់គរុនិស្សិត<br>- ព័ត៌មានត្រឡប់ពីគរុនិស្សិត<br>- វីដេអូ ឬសំឡេងក្នុងការបង្រៀន<br>- កម្មវិធីសិក្សាលម្អិត<br>- កិច្ចតែងការបង្រៀន<br>- ឧបករណ៍វាយតម្លៃ<br>- កិច្ចការផ្ទះតាមមុខវិជ្ជាសិក្សា |
| | ១.៣.២.យល់ដឹងពីរបៀបរៀនរបស់គរុនិស្សិត | |
| | ១.៣.៣. មានចំណេះដឹងផ្នែកគរុកោសល្យនិងវិធីសាស្ត្របង្រៀន | |
| | ១.៣.៤.យល់ដឹងពីរបៀបរៀនរបស់គរុនិស្សិតសម្រាប់មុខវិជ្ជារួម និងមុខវិជ្ជាឯកទេស | |
| | ១.៣.៥.ប្រើប្រាស់យុទ្ធវិធីបង្រៀនសមស្របនឹងសមត្ថភាព និងចំណង់ចំណូលចិត្តរបស់គរុនិស្សិត និងឈានទៅសម្រេចវត្ថុបំណងនៃមេរៀន | |
| ១.៤. ចំណេះដឹងលើបរិបទអប់រំ | ១.៤.១. យល់ដឹងពីច្បាប់ គោលនយោបាយ និងប្រព័ន្ធអប់រំនៅកម្ពុជា | បកស្រាយបានពីៈ<br>- ច្បាប់អប់រំនៅកម្ពុជា<br>- ប្រព័ន្ធអប់រំនៅកម្ពុជា<br>- គោលការណ៍របស់ក្រសួង<br>- ការអប់រំប្រកបដោយចីរភាព |
| | ១.៤.២. យល់ដឹងអំពីប្រព័ន្ធអប់រំថ្នាក់តំបន់ និងសាកលលោក | |
| | ១.៤.៣. យល់ដឹងពីបញ្ហាប្រឈមក្នុងវិស័យអប់រំនាពេលបច្ចុប្បន្ន | |



Khmer Law Association, www.khmerlaw.org

| ស្តង់ដាទី២៖. ការប្រតិបត្តិវិជ្ជាជីវៈ | សូចនាករ | ភស្តុតាងសំខាន់ៗ |
|---|---|---|
| ២.១. ការការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត | ២.១.១. រៀបចំកិច្ចតែងការបង្រៀនត្រឹមត្រូវនិងមានប្រសិទ្ធភាព | - កម្មវិធីសិក្សាលម្អិត<br>- ឧបករណ៍រង្វាយតម្លៃ<br>- កិច្ចការតាមមុខវិជ្ជា រៀបចំដោយគ្រូឧទ្ទេស<br>- កិច្ចតែងការបង្រៀនមានវត្ថុបំណងច្បាស់លាស់ សកម្មភាពរៀន និងបង្ហាញពីរបៀបវាយតម្លៃលទ្ធផលសិក្សាច្បាស់លាស់<br>- សន្លឹកកិច្ចការតេស្ត វិញ្ញាសាប្រឡង និងអត្រាកំណែជាមួយនឹងនិទ្ទេសបទច្បាស់លាស់<br>- របាយការណ៍លទ្ធផលស្តីពីការធ្វើតេស្ត ការប្រឡង និងការវាយតម្លៃ<br>- កំណត់ត្រាការសង្កេត<br>- របាយការណ៍ និងកំណត់ត្រាស្តីពីការរីកចម្រើនរបស់គរុនិស្សិត<br>- របាយការណ៍ស្តីពីការផ្តល់ព័ត៌មានត្រឡប់ដល់គរុនិស្សិត និងអាណាព្យាបាល<br>- ព្រឹត្តបត្រ និងវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់គរុនិស្សិត<br>- របាយការណ៍តាមដានការសិក្សារបស់គរុនិស្សិត<br>- របាយការណ៍ស្វ័យវាយតម្លៃ |
| | ២.១.២.រៀបចំសម្ភារឧបទេសមានប្រសិទ្ធភាពដើម្បីសម្រេចបានលទ្ធផលសិក្សារបស់គរុនិស្សិត | |
| | ២.១.៣. ប្រើប្រាស់វិធីសាស្ត្រវាយតម្លៃផ្សេងៗសមស្របនឹងការសិក្សារបស់គរុនិស្សិត | |
| | ២.១.៤. វាយតម្លៃការសិក្សារបស់គរុនិស្សិតប្រកបដោយទំនុកចិត្ត សុពលភាព និងតម្លាភាព | |
| | ២.១.៥.តាមដានការចូលរួមនិងការអភិវឌ្ឍរបស់គរុនិស្សិត | |
| | ២.១.៦.បង្ហាញរង្វាយតម្លៃការអប់រំដែលមានលក្ខណៈជាប្រព័ន្ធមួយច្បាស់លាស់ | |
| | ២.១.៧. វិភាគនិងប្រើប្រាស់លទ្ធផលតេស្ត ដើម្បីពង្រឹងប្រសិទ្ធភាពនៃរៀន និងបង្រៀន | |
| | ២.១.៨.ផ្តល់ព័ត៌មានត្រឡប់ដល់គរុនិស្សិត អាណាព្យាបាលពីការរីកចម្រើនរបស់ពួកគេទាំងផ្នែកចំណេះដឹង បំណិន និងឥរិយាបថ | |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| ២.២. ការគ្រប់គ្រងបរិស្ថានសិក្សា | ២.២.១. ផ្តល់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និង លើកទឹកចិត្តដល់ការសិក្សា<br>២.២.២.ជួយគរុនិស្សិតឱ្យមានទំនួលខុសត្រូវខ្ពស់ក្នុងការសិក្សា<br>២.២.៣.ចូលរួមអភិវឌ្ឍវិទ្យាស្ថានដើម្បីគាំទ្រដល់ការសិក្សា និងសុខុមាលភាពរបស់គរុនិស្សិត<br>២.២.៤. អនុវត្ត ដឹកនាំការសិក្សាវិជ្ជាជីវៈរបស់គរុនិស្សិត<br>២.២.៥. ជួយគរុនិស្សិតក្នុងការរៀបចំការសិក្សានិងកម្មសិក្សាគរុកោសល្យ<br>២.២.៦. គ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និង ការសហការល្អ | - កម្មវិធីសិក្សាលម្អិត<br>- កិច្ចតែងការបង្រៀន<br>- ឧបករណ៍វង្វាយតម្លៃ<br>- កិច្ចការសម្រាប់មុខវិជ្ជាសិក្សាណាមួយ<br>- របាយការណ៍ស្វ័យវាយតម្លៃ<br>- របាយការណ៍ពិនិត្យតាមដានគរុនិស្សិត<br>- បញ្ជីវត្តមានចូលរួមវគ្គសិក្ខាសាលា<br><br>- ផែនការ និងសកម្មភាពរៀបចំបរិស្ថានសិក្សាជុំវិញ និងក្នុងថ្នាក់រៀន<br>- របាយការណ៍សង្កេតថ្នាក់រៀន<br>- របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំ<br>- រចនាសម្ពន្ធការងាររបស់គរុនិស្សិតដើម្បីធានាបាននូវបរិស្ថានសិក្សាស្អាត |
| ២.៣. វិធីសាស្ត្របង្រៀន | ២.៣.១. ប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងៗដើម្បីគាំទ្រដល់របៀបរៀនសមស្របរបស់គរុនិស្សិត<br>២.៣.២.រៀបចំនិងផ្តល់ឱកាសសម្រាប់គរុនិស្សិតក្នុងការសិក្សានិងដោះស្រាយបញ្ហាប្រឈមប្រកបដោយសុក្រិតភាពនិងគំនិតច្នៃប្រឌិត<br>២.៣.៣.ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីទទួលបានប្រសិទ្ធភាពនៃការបង្រៀននិងរៀន | - កម្មវិធីសិក្សាលម្អិត<br>- កិច្ចតែងការបង្រៀន<br>- ឧបករណ៍វាយតម្លៃ<br>- កិច្ចការរបស់គរុនិស្សិត<br>- វីដេអូឬសំឡេង និងពហុព័ត៌មាន<br>- របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំ |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| | ២.៣.៤.ប្រើប្រាស់វិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិតដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត | -បញ្ជីវត្តមានការចូលរួមវគ្គសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន<br>-របាយការណ៍សង្កេតថ្នាក់រៀនលើការប្រើប្រាស់ICT ក្នុងការបង្រៀននិងរៀន<br>-កិច្ចការតាមមុខវិជ្ជាសិក្សា |
| ២.៤. កិច្ចសហការ | ២.៤.១. បង្កើតបណ្តាញទំនាក់ទំនងនិងសហការរវាងគរុនិស្សិត សហគមន៍គ្រូឧទ្ទេសក្នុងនិងក្រៅវិទ្យាស្ថាន<br>២.៤.២. សហការជាប្រចាំជាមួយភាគីពាក់ព័ន្ធដើម្បីលើកកម្ពស់ប្រសិទ្ធភាពការបង្រៀន រៀន និងស្រាវជ្រាវអប់រំ | -របាយការណ៍ស្វ័យវាយតម្លៃ<br>-របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំ<br>-កម្មវិធីសិក្សាលម្អិត<br>-កិច្ចតែងការបង្រៀន<br>- ឧបករណ៍វាយតម្លៃ<br>-តំណាងគំរូកិច្ចការរបស់គរុនិស្សិត<br>-កិច្ចការសម្រាប់មុខវិជ្ជាណាមួយ<br>-ការត្រួតពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំ |



Khmer Law Association, www.khmerlaw.org

| ស្តង់ដាទី៣៖ ការអភិវឌ្ឍវិជ្ជាជីវៈ | សូចនាករ | លទ្ធផល/ ភស្តុតាងបង្ហាញ |
|---|---|---|
| ៣.១. ស្វ័យសិក្សា និងការឆ្លុះបញ្ចាំង | ៣.១.១. ដឹងពីចំណុចខ្លាំង ចំណុចខ្សោយ និងតម្រូវការបន្ថែម ដើម្បីរៀបចំផែនការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ | -ភស្តុតាងនៃគោលដៅនិងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ<br>-ផែនការអភិវឌ្ឍវិជ្ជាជីវៈ<br>-របាយការណ៍ស្វ័យឆ្លុះបញ្ចាំងឬស្វ័យវាយតម្លៃ<br>-បញ្ជីវត្តមានការចូលរួមសិក្ខាសាលា<br>-ការបោះពុម្ពរួមគ្នា<br>-របាយការណ៍ឆ្លុះបញ្ចាំង<br>-វិញ្ញាបនបត្របញ្ជាក់លើការសិក្សាជំនាញបន្ថែម<br>-សញ្ញាបត្រ<br>-កម្មវិធីសន្និសីទ<br>-កិច្ចព្រមព្រៀង |
| | ៣.១.២. ធ្វើស្វ័យវាយតម្លៃជាប្រចាំលើការអនុវត្តផែនការអភិវឌ្ឍវិជ្ជាជីវៈ | |
| | ៣.១.៣.ប្រើប្រភពផ្សេងៗដើម្បីវាយតម្លៃលើការអនុវត្តរបស់ខ្លួន | |
| | ៣.១.៤. ស្វ័យឆ្លុះបញ្ចាំងលើការអនុវត្តការបង្រៀនរបស់ខ្លួនជាលក្ខណៈប្រព័ន្ធនិងទៀងទាត់ | |
| | ៣.១.៥. អភិវឌ្ឍចំណេះដឹងលើជំនាញបច្ចេកវិទ្យាអនុវត្តក្នុងការបង្រៀននិងរៀន | |
| | ៣.១.៦. តម្រូវការជំនាញភាសាអង់គ្លេសយ៉ាងហោចណាស់កម្រិតមធ្យម( intermediate ) | |
| ៣.២. ការចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ៣.២.១. ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលាលើកកម្ពស់គុណវុឌ្ឍិ សន្និសីទជាតិ និងអន្តរជាតិដើម្បីអភិវឌ្ឍវិជ្ជាជីវៈ | -កម្មវិធីសិក្សាលម្អិត<br>-កិច្ចតែងការបង្រៀន<br>-អត្ថបទវិជ្ជាជីវៈដែលបានអាន<br>-បញ្ជីវត្តមានការចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល<br>-វិញ្ញាបនបត្រការសិក្សាជំនាញបន្ថែម<br>-របាយការណ៍ស្វ័យឆ្លុះបញ្ចាំងឬស្វ័យវាយតម្លៃ |
| | ៣.២.២.ប្រាស្រ័យទាក់ទងជាមួយគ្រូឧទ្ទេសក៏ដូចជាគ្រូបង្រៀនដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈ | |
| ៣.៣. ចូលជាសមាជិកភាពនៃសហគមន៍វិជ្ជាជីវៈ | ៣.៣.១.ចែករំលែកឧត្តមានុវត្តក្នុងសហគមន៍វិជ្ជា ជីវៈ | -បញ្ជីវត្តមានចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល |
| | ៣.៣.២.ចែករំលែកបទពិសោធអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន | |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| | ៣.៣.៣.ចូលរួមនិងឆ្លុះបញ្ចាំងសកម្មភាពរៀនសូត្រនៅក្នុងសហគមន៍វិជ្ជាជីវៈគ្រូបង្រៀននិង សង្គមបញ្ញវន្ត | -វិញ្ញាបនបត្រជំនាញបន្ថែម<br>-របាយការណ៍ស្វ័យឆ្លុះបញ្ចាំងឬស្វ័យវាយតម្លៃ<br>-លិខិតឬបណ្ណបញ្ជាក់សមាជិកភាពនៃសហគមន៍វិជ្ជាជីវៈ<br>-បទបង្ហាញ របាយការណ៍ស្រាវជ្រាវពាក់ព័ន្ធនឹងវិជ្ជាជីវៈ<br>-លិខិតឧទ្ទេសនាមចូលរួម<br>-វិញ្ញាបនបត្រសិក្សា |
| **ស្តង់ដាទី៤៖ សីលធម៌វិជ្ជាជីវៈ** | **សូចនាករ** | **ភស្តុតាងសំខាន់ៗ** |
| ៤.១. ការយកចិត្តទុកដាក់ចំពោះគរុនិស្សិត | ៤.១.១. យកចិត្តទុកដាក់ដល់គរុនិស្សិតនិងប្រយោជន៍របស់គរុនិស្សិត<br>៤.១.២. មានទំនាក់ទំនងប្រកបដោយសុខដុមនីយកម្មចំពោះគរុនិស្សិតនិងសហគមន៍វិជ្ជាជីវៈ<br>៤.១.៣. ដោះស្រាយបញ្ហាដោយយុត្តិធម៌និងតម្លាភាព | បញ្ជីវត្តមានអ្នកចូលរួមព្រឹត្តិការណ៍របស់វិទ្យាស្ថាន<br>កម្មវិធីសិក្សាលម្អិត<br>កិច្ចតែងការបង្រៀន<br>តំណាងគំរូកិច្ចការរបស់គរុនិស្សិត<br>សម្ភារៈឧបទេស<br>វីដេអូ និងសំឡេងនៃការបង្រៀន<br>របាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីអប់រំ |
| ៤.២. ការប្តេជ្ញាចិត្តនិងទំនួលខុសត្រូវលើវិជ្ជាជីវៈគ្រូបង្រៀន | ៤.២.១. គោរពក្រមសីលធម៌វិជ្ជាជីវៈ សុជីវធម៌ក្នុងការរស់នៅ និងតម្លៃជាគ្រូឧទ្ទេសល្អ<br>៤.២.២. មានអាកប្បកិរិយារួសរាយរាក់ទាក់និងសុភាពរាបសារ | បញ្ជីវត្តមានប្រចាំថ្ងៃរបស់បុគ្គលិក<br>បញ្ជីវត្តមានអ្នកចូលរួមគ្រប់ព្រឹត្តិការណ៍របស់វិទ្យាស្ថាន<br>របាយការណ៍ស្តីពីសកម្មភាពវិជ្ជាជីវៈ |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| | ៤.២.៣. បង្ហាញភាពរីករាយនិងគំនិតផ្តួចផ្តើមនៅគ្រប់ទិដ្ឋភាពនៃសកម្មភាពវិជ្ជាជីវៈ | របាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីអប់រំ |
| ៤.៣. ការធ្វើជាគំរូវិជ្ជមាននៃតម្លៃចរិយាធម៌ | ៤.៣.១. មានសុចរិតក្នុងវិជ្ជាជីវៈ | បទបញ្ជាផ្ទៃក្នុងសម្រាប់បុគ្គលិកអប់រំរបស់វិទ្យាស្ថាន<br>របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំ<br>របាយការណ៍ស្វ័យឆ្លុះបញ្ចាំង( ស្វ័យវាយតម្លៃ )<br>បណ្ណសរសើរ |
| | ៤.៣.២. យល់ដឹងលើក្រមសីលធម៌វិជ្ជាជីវៈនិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | |
| | ៤.៣.៣. បង្ហាញការគោរពគ្នាទៅវិញទៅមករវាងគរុនិស្សិត និងសហគមន៍វិជ្ជាជីវៈ និងរក្សាទំនាក់ទំនងប្រកបដោយសុខដុមរមនា | |
| | ៤.៣.៤. បង្ហាញពីការចូលរួមប្រកបដោយវិជ្ជាជីវៈក្នុងសហគមន៍ចម្រុះ | |
| | ៤.៣.៥. បណ្តុះគុណតម្លៃចរិយាធម៌ដល់គរុនិស្សិត និងអ្នកដទៃ | |
| ៤.៤. សមត្ថភាពលើកកម្ពស់វប្បធម៌ និងយុត្តិធម៌ក្នុងការអប់រំ | យល់ដឹងពីវប្បធម៌ | ភស្តុតាននៃការលើកកម្ពស់យុត្តិធម៌សង្គម<br>របាយការណ៍ស្វ័យឆ្លុះបញ្ចាំង( ស្វ័យវាយតម្លៃ ) |
| | លើកកម្ពស់យុត្តិធម៌សង្គមក្នុងការអប់រំគ្រូបង្រៀន | |
| | បង្ហាញពីភាពមិនរើសអើង | |
| ៤.៥. ការវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត | ៤.៥.១. វាយតម្លៃលទ្ធផលសិក្សាប្រកបដោយយុត្តិធម៌ | កម្មវិធីសិក្សាលម្អិត<br>ឧបករណ៍វាយតម្លៃ<br>វិញ្ញាសានិងអត្រាកំណែ<br>តារាងពិន្ទុប្រចាំឆមាស<br>តារាងវាយតម្លៃកម្មសិក្សាគរុកោសល្យ |
| | ៤.៥.២. ចែករំលែកវិធីសាស្ត្រវាយតម្លៃគរុនិស្សិតជាមួយនឹងគ្រូឧទ្ទេសដទៃទៀត | |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| | ៤.៥.៣. បន្ស៊ីវិធីសាស្ត្រវាយតម្លៃគរុនិស្សិតជាមួយគ្រូឧទ្ទេសដទៃទៀត | តំណាងគំរកិច្ចការរបស់គរុនិស្សិត<br>របាយការណ៍វាយតម្លៃនិងការប្រឡង<br>របាយការណ៍ស្វ័យឆ្លុះបញ្ចាំង( ស្វ័យវាយតម្លៃ )<br>របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំនិងវាយតម្លៃលទ្ធផល |
| **ស្តង់ដាទី៥៖ ការស្រាវជ្រាវអប់រំ** | **សូចនាករ** | **លទ្ធផល/ ភស្តុតាងបង្ហាញ** |
| ៥.១. ចំណេះដឹង និងជំនាញស្រាវជ្រាវអប់រំ | ៥.១.១. បង្ហាញគុណវុឌ្ឍិស្រាវជ្រាវអប់រំច្បាស់លាស់ | សំណើស្រាវជ្រាវ<br>ផែនការស្រាវជ្រាវ<br>របាយការណ៍ស្រាវជ្រាវ<br>ការស្ទង់មតិទាក់ទងនឹងការស្រាវជ្រាវអប់រំ<br>បទបង្ហាញមុខវិជ្ជាដូចជា PPT វីដេអូ ឬសំឡេង<br>របាយការណ៍វិចារណនិពន្ធ<br>របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំនិងការវាយតម្លៃលទ្ធផល |
| | ៥.១.២.បន្ស៊ីវិធីសាស្ត្រស្រាវជ្រាវឱ្យស្របតាមបរិបទជាក់ស្តែង | |
| | ៥.១.៣. ដឹកនាំនិងវាយតម្លៃការស្រាវជ្រាវអប់រំរបស់គរុនិស្សិត | |
| ៥.២. ការអនុវត្តការស្រាវជ្រាវអប់រំ | ៥.២.១.រៀបចំផែនការស្រាវជ្រាវអប់រំ | កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា<br>កិច្ចតែងការបង្រៀន<br>សំណើស្រាវជ្រាវ<br>របាយការណ៍ស្រាវជ្រាវ |
| | ៥.២.២.ជ្រើសរើសនិងអនុវត្តវិធីសាស្ត្រស្រាវជ្រាវសមស្រប | |
| | ៥.២.៣.ជ្រើសរើសនិងអនុវត្តវិធីសាស្ត្រស្រាវជ្រាវសមស្រប | |



Khmer Law Association, www.khmerlaw.org

| | | |
|---|---|---|
| | ៥.២.៤.ធ្វើការវិភាគនិងឆ្លុះបញ្ចាំងទៅលើលទ្ធផលនៃការស្រាវជ្រាវអប់រំ | សៀវភៅស្រាវជ្រាវដែលបានបោះពុម្ពនិងបទបង្ហាញ<br>ឯកសារបទបង្ហាញដែលបានរៀបចំសម្រាប់សន្និសីទ សិក្ខាសាលាពីលទ្ធផលនៃការស្រាវជ្រាវ<br>បទបង្ហាញដូចជា PPT វីដេអូ និងជាសំឡេង<br>របាយការណ៍ស្វ័យវាយតម្លៃ<br>របាយការណ៍ឆ្លុះបញ្ចាំងអត្ថបទស្រាវជ្រាវ<br>សង្ខិត្តកថា(មូលន័យសង្ខេប)<br>បញ្ជីវត្តមានអ្នកចូលរួមសិក្ខាសាលា<br>បទបង្ហាញនៅពេលសិក្ខាសាលា<br>របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំនិងការវាយតម្លៃលទ្ធផល |
| | ៥.២.៥.ឆ្លុះបញ្ចាំងពីផលប៉ះពាល់ដល់ក្រមសីលធម៌ ការអនុវត្ត និងចំណេះដឹង | |
| | ៥.២.៦.ឆ្លុះបញ្ចាំងពីដែនកំណត់នៃវិធីសាស្ត្រស្រាវជ្រាវ | |
| | ៥.២.៧.រៀបចំនិងអនុវត្តការស្រាវជ្រាវអប់រំ(ប្រតិបត្តិ) | |
| | ៥.២.៨.ប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវដើម្បីបម្រើការអប់រំ | |
| | ៥.២.៩.បង្ហាញពីបំណិនសរសេរដែលចាំបាច់ក្នុងការសរសេរសេចក្តីផ្តើម វិធីសាស្ត្រ លទ្ធផល និងផ្នែកនានានៃការពិភាក្សាពីនិក្ខេបបទ | |
| | ៥.២.១០. សរសេរអត្ថបទបោះពុម្ពបែបសិក្សា និងបែបវិទ្យាសាស្ត្រ | |
| | ៥.២.១១.ធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវ | |
| | ៥.២.១២.បោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវទាំងក្នុងនិងក្រៅវិទ្យាស្ថាន | |
| | ៥.២.១៣.សង្ខិតកថា(មូលន័យសង្ខេប)ទាន់ពេលពេលវេលាទៅកម្មវិធីសន្និសីទ សិក្ខាសាលាសម្រាប់ការធ្វើបទបង្ហាញ | |



Khmer Law Association, www.khmerlaw.org

| ស្តង់ដាទី៦៖ ការអភិវឌ្ឍកម្មវិធីអប់រំ | សូចនាករ | ភស្តុតាងសំខាន់ៗ |
|---|---|---|
| ៦.១. ការអភិវឌ្ឍ និងការកែលម្អកម្មវិធីអប់រំ | ៦.១.១.ចូលរួមចំណែកយ៉ាងសកម្មក្នុងការកែលម្អកម្មវិធីសិក្សានិងមុខវិជ្ជាសិក្សា | គម្រោងវគ្គសិក្សា មុខវិជ្ជា និងកម្មវិធីអប់រំ<br>ការពិនិត្យឡើងវិញវគ្គសិក្សា មុខវិជ្ជា និងកម្មវិធីអប់រំ<br>សម្ភារសិក្សាថ្មីៗត្រូវបានផលិតដើម្បីកែលម្អវគ្គសិក្សា មុខវិជ្ជា និងកម្មវិធីអប់រំ<br>អត្ថបទបោះពុម្ព ឯកសារចែកជូន ឬឯកសារផ្សេងៗទៀតស្តីពីការអភិវឌ្ឍកម្មវិធីអប់រំ |
| | ៦.១.២.ចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសម្ភារៈឧបទេសថ្មីៗ | |
| | ៦.១.៣.រៀបចំ អភិវឌ្ឍ និងកែលម្អកម្មវិធីអប់រំគ្រូបង្រៀនដោយផ្អែកលើទ្រឹស្តី ការស្រាវជ្រាវ និងឧត្តមានុវត្តបានល្អប្រសើរ<br>៦.១.៤.ចូលរួមចំណែកធ្វើយ៉ាងណាឱ្យកម្មវិធីអប់រំគ្រូបង្រៀនមានការទទួលស្គាល់ | |
| | ៦.១.៥.<br>ចូលរួមចំណែកស្រាវជ្រាវដែលផ្តោតលើការកែលម្អ កម្មវិធីអប់រំប្រកបដោយប្រសិទ្ធភាព | |
| ៦.២. ការវាយតម្លៃកម្មវិធីអប់រំ | ៦.២.១.ចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាគុណភាពអប់រំផ្ទៃក្នុង | បញ្ជីវគ្គមានអ្នកចូលរួមក្នុងពិនិត្យឡើងវិញនិងវាយតម្លៃកម្មវិធីអប់រំ<br>បញ្ជីសម្ភារឧបទេសដែលបានផលិត<br>បញ្ជីឈ្មោះអ្នកចូលរួមក្នុងការវាយតម្លៃកម្មវិធីអប់រំ<br>របាយការណ៍វាយតម្លៃកម្មវិធីអប់រំ |
| | ៦.២.២.ចូលរួមចំណែកយ៉ាងសកម្មក្នុងការពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីអប់រំជាប្រចាំ | |
| | ៦.២.៣.ចូលរួមយ៉ាងសកម្មក្នុងការធ្វើស្វ័យវាយតម្លៃមុខវិជ្ជានិងកម្មវិធីសិក្សាលម្អិតជាប្រចាំ | |
| | ៦.២.៤.ចូលរួមចំណែកក្នុងការរៀបចំស្តង់ដាសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនរបស់វិទ្យាស្ថាន | |



Khmer Law Association, www.khmerlaw.org